# ការសំភាសន៍របស់ អ្នកមីង ប្រាក់ ជា

ក៖ អ្នកធ្វើការសំភាសន៍ គីម ម៉េង ខ៖ អ្នកដែលត្រូវបានគេសំភាសន៍ឈ្មោះ ប្រាក់ ជា

## ការសង្ខេបរបស់លោកយាយ ប្រាក់ ជា

អ្នកមីង ប្រាក់ ជា គាត់មានអាយុ ៦៨ឆ្នាំ ក្នុងឆ្នាំ ២០១៨អ្នកមីង ប្រាក់ ជាមានភេទស្រីអ្នកមីង ប្រាក់ ជាមានទីលំនៅនាពេលបច្ចុប្បន្ននៅភូមិក្រោកគោ សង្កាត់គីឡូរម៉ែត្រលេខ៦ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ។

ក៖
ចឹងជាដំបូងជំរាបសួរលោកយាយខ្ញុំបាទមកពីរខាងសាកលវិទ្យាល័យបីបាយយូនៃសហរដ្ឋអាមេរិចហើយមានការអញ្ជើញដើម្បីមានការសំភាសន៍លោកយាយអំពីពង្សប្រវត្តិតតើអ្នកមីងអាយអនុញ្ញាត្តិអោយសំភាសន៍អ្នកមីងពង្សប្រវត្តិអ្នកមីងបានដែលទេ???

ខ៖ ចាសបាន ៕

ក៖
ចឹងថ្ងៃនេះគឺជាថ្ងៃដែលខ្ញុំបានសំភាសន៍អ្នកមីងគឺជាថ្ងៃទី០៥ខែ០៥(ឧសភា)ឆ្នាំ២០១៨ហើយធ្វើការសំភាសន៍ដោយរូបខ្ញុំបាទឈ្មោះគីមម៉េងហើយនាក់សំភាសន៍អ្នកមីងឈ្មោះអ្នកមីងស្រៀង ប្រាក់ ជា
ចឹងផ្ដើមឈ្មោះដំបូងខ្ញុំអាចស្គាល់ឈ្មោះរបស់អ្នកមីងបានដែលរឺទេអ្នកមីង???

ខ៖ ចាសបានខ្ញុំឈ្មោះ ប្រាក់ ជា៕

ក៖ បាទហើយចឹងសំណួរដែលខ្ញុំចង់សួរអ្នកមីងដំបូងគឺឈ្មោះរបស់អ្នកមីងពេញហើយនឹងព្រមទាំងត្រគោលរបស់អ្នកមីងមានឈ្មោះអ្វីដែលទៅអ្នកមីង???

ខ៖ ចាសសំរាប់ឈ្មោះរបស់ខ្ញុំនឹងគឺខ្ញុំមានឈ្មោះតែមួយនោះទេគឺឈ្មោះ ប្រាក់ ជា ៕

ក៖ បាទហើយសំរាប់អ្នកមីងមានឈ្មោះហៅក្រៅដែលរឺទេអ្នកមីអង???

ខ៖ ចាសសំរាប់គឺគ្មានឈ្មោះហៅក្រៅនោះទេចាស៕

ក៖ បាទហើយចឹងសំរាប់ឆ្នាំនឹងថាតើអ្នកមីងមានអាយុប៉ុន្មានឆ្នាំហើយអ្នកមីង???

ខ៖ ចាសសំរាប់ឆ្នាំនឹងគឺខ្ញុំមានអាយុ ៦៨ឆ្នាំហើយចាស៕

កៈ

បាទហើយចឹងរាល់ថ្ងៃនឹងថាតើអ្នកមីងមានទីកន្លែងកំណើតនៅទីកន្លែងណាដែលទៅអ្នកមីង???

ខៈ

ចាសសំរាប់ស្រុកកំណើតរបស់ខ្ញុំនឹងគឺនៅស្រុកវៀតណាមនោះទេចាសនិយាយទៅគឺខ្ញុំគឺជាប្រជាជនកម្មកម្ពុជាក្រោមនោះទេចាស៕

កៈ

បាទហើយសំរាប់ស្រុកកំណើតរបស់អ្នកមីងដែលនៅស្រុកវៀតណាមនឹងនៅស្រុកអ្វីហើយនឹងខេត្តអ្វីដែលទៅអ្នកមីងអាចប្រាប់ខ្ញុំបានដែលរឺទេអ្នកមីង???

ខៈ

ចាសសំរាប់ស្រុករបស់ខ្ញុំនឹងគឺនៅស្រុកខែត្រពាំងហើយក៏ខេត្តព្រះត្រពាំងដែលចាសនិយាយទៅខេត្តហើយនឹងស្រុកឈ្មោះដូចគ្នាចាស៕

កៈ បាទហើយចឹងសំរាប់អ្នកមីងសព្វថ្ងៃនឹងមានកូនចំនួនប៉ុន្មាននាក់ដែលទៅអ្នកមីង???

ខៈ ចាសសំរាប់ខ្ញុំសព្វគឺខ្ញុំនឹងមានកូនចំនួន
៧នាក់ហើយគេនៅទាំង៧នាក់នឹងតែម្តងហាសចាសតែសំរាប់តារបស់ខ្ញុំនឹងគឺគាត់បានស្លាប់ហើយចឹងហាសចាសហើយនៅពេលដែលតារបស់ខ្ញុំនឹងគាត់បាននៅរស់គឺគាត់ធ្វើជាទាហ៊ានអាមរិចកាំងគាត់មិនដែលធ្វើជាទាហ៊ានខ្មែរនោះទេចាសហើយសំរាប់នៅក្នុងជំនាន់នឹងគឺគាត់បានប្តូរមកធ្វើជាទាហ៊ានខ្មែរវិញនឹងចាស៕

កៈ បាទហើយចឹងអ្នកមីងមានបានចាំឈ្មោះកូនរបស់អ្នកមីងទាំង
៧នាក់នឹងដែលរឺទេលោកអ្នកមីង???

ខៈ ចាសគឺខ្ញុំនៅចាំចាស៕

កៈ

បាទហើយចឹងអ្នកមីងអាចប្រាប់ឈ្មោះកូនរបស់អ្នកមីងម្តងម្នាក់ម្តងម្នាក់បានដែលរឺទេអ្នកមីង???

ខៈ ចាសសំរាប់កូនទី១របស់ខ្ញុំនឹងគាត់មានឈ្មោះថា គាង ម៉ៅ
ហើយសំរាប់កូនទី២របស់ខ្ញុំនឹងគាត់មានឈ្មោះថា គាង  វណ្ណនី (ប្រុស)
ហើយសំរាប់កូនទី៣របស់ខ្ញុំនឹងគាត់មានឈ្មោះថា គាង វណ្ណណាក់
ហើយសំរាប់កូនទី៤របស់ខ្ញុំនឹងគាត់មានឈ្មោះថា គាង ពៅ (ស្រី)
ហើយសំរាប់កូនទី៥របស់ខ្ញុំនឹងគាត់មានឈ្មោះថា គាង ឡា (ប្រុស) មួយទៀត
ហើយសំរាប់កូនទី៦របស់ខ្ញុំនឹងគាត់មានឈ្មោះថា គាង ទូច

ហើយសំរាប់កូនទី៧របស់ខ្ញុំនឹងគាត់មានឈ្មោះថា គាង ចាន់ថា សរុប៧នាក់ហើយសំរាប់៧នាក់នឹងគឺតែរស់នៅទាំងអស់នឹងហាសចាស៕

កៈ
បាទហើយសំរាប់រាល់ថ្ងៃនឹងថាតើពួកគាត់ទាំងអស់មានគ្រួសារហើយអស់រឺក៏យ៉ាងមិចដែលទៅអ្នកមីង???

ខៈ
ចាសសំរាប់រាល់ថ្ងៃនឹងគឺគេមានគ្រួសារអស់ហើយចាសហើយសំរាប់២នាក់ស្រីនឹងគឺគេបានរស់នៅខេត្តសៀមរាបឯនោះចាសគឺអត់មានរស់នៅទីកន្លែងនឹងទេហាសហើយសំរាប់កូនប្រុសខ្លះរបស់ខ្ញុំនឹងគឺរស់នៅសាលាលេខ៥ហាសហើយសំរាប់ខ្លះទៀតគាត់រស់នៅខេត្តព្រៃវែងឯងនោះចាសហើយសំរាប់កូនរបស់ខ្ញុំនឹងគឺគេបានទៅធ្វើការងារអស់ហើយគឺរស់នៅតែខ្ញុំនឹងហាសចាស៕

កៈ
បាទហើយចឹងអរគុណច្រើនអ្នកមីងហើយចឹងឪពុករបស់អ្នកមីងគាត់មានឈ្មោះអ្វីដែល???

ខៈ
ចាសសំរាប់ឪពុករបស់ខ្ញុំគឺខ្ញុំមិនបានស្គាល់ឈ្មោះគាត់ទេពីព្រោះអីនឹងគឺខ្ញុំនឹងគឺជាក្មេងកំព្រាតាំងពីខ្ញុំនៅក្មេងមកម្លេះចាស៕

កៈបាទហើយចឹងសំរាប់របស់អ្នកមីងវិញគាត់មានឈ្មោះអ្វីដែលទៅ???

ខៈ
ចាសសំរាប់ម្ដាយរបស់ខ្ញុំនឹងក៏ដូចគ្នាដែលគឺខ្ញុំនឹងមានតែម្ដាយចិញ្ចឹមនោះទេចាសនិយាយទៅគឺខ្ញុំនឹងមិនបានស្គាល់ឈ្មោះម្ដាយហើយនឹងឪពុករបស់ខ្ញុំនឹងនោះទេទេពីព្រោះអីនឹងគឺខ្ញុំនឹងគឺជាក្មេងកំព្រាតាំងពីខ្ញុំនៅក្មេងមកម្លេះចាស៕

កៈ បាទហើយចឹងអ្នកមីងគឺជាកូនកំព្រាមែនដែលទេអ្នកមីង???

ខៈ ចាសខ្ញុំនឹងគឺជាកូនកំព្រា៕

កៈ បាទហើយចឹងរាល់ថ្ងៃនឹងថាតើអ្នកមីងប្រកបមុខរបបអ្វីដែលទៅអ្នកមីង???

ខៈ
ចាសសំរាប់ខ្ញុំរាល់ថ្ងៃនឹងគឺខ្ញុំមិនបានប្រកបមុខរបបអ្វីនោះទេចាសគឺខ្ញុំនឹងនៅតែផ្ទះនោះទេពីព្រោះអីនឹងកូនរបស់ខ្ញុំនឹងគឺគេមិនចង់អោយខ្ញុំនឹងធ្វើការងារអ្វីនោះទេចាសពីព្រោះអីនឹងកូនខ្លះនឹងគេបានអោយបន្តិចទៅហើយកូនខ្លះទៀតគេអោយបន្តិចចឹងទៅចាសហើយសំរាប់កូនប្រុសរបស់ខ្ញុំនឹងគឺគេអោយបានបន្តិចចឹងទៅហើយគេមិនបានអោយខ្ញុំនឹងទៅលក់

ទៅដូរអ្វីនោះទេចាសនិយាយទៅកូនរបស់ខ្ញុំនឹងគេទៅធ្វើការងារតាំង៣យប់រហូតដល់ម៉ោង៥អីនឹងរហូតដល់មាន់រងាវអីនោះបានគេបានចូលផ្ទះចឹងហាសហើយនៅពេលដែលខ្ញុំនឹងបានការកូនរបស់ខ្ញុំអស់ហើយគឺខ្ញុំនឹងចាប់ផ្តើមដើលលក់ហើយចឹងហាសចាស៕

ក៖ បាទហើយសំរាប់ពីមុននឹងអ្នកមីងលក់អ្វីដែលទៅអ្នកមីង???

ខ៖
ចាសសំរាប់ពីមុននឹងគឺខ្ញុំនឹងលក់គ្រាប់មុខនឹងអ្វីក៏ខ្ញុំលក់ដែលចឹងហាសចាសនិយាយទៅតាំងពីសណ្តែកដីហើយនឹងប្រិនហើយនឹងលាសហើយនឹងខ្ទៅគឺខ្ញុំលក់ទាំងអស់នឹងចាស៕

ក៖
បាទហើយចឹងខ្ញុំចង់សួរសំណួរអ្នកមីងមួយទៀតថាតើស្វាមីរបស់អ្នកមីងគាត់មានឈ្មោះអ្វីដែលទៅអ្នកមីង???

ខ៖ ចាសសំរាប់ស្វាមីរបស់ខ្ញុំនឹងគឺគាត់មានឈ្មោះ ចៅ គាង ៕

ក៖ ហើយសំរាប់ស្វាមីរបស់អ្នកមីងគាត់មានអាយុប៉ុន្មានឆ្នាំហើយអ្នកមីង???

ខ៖ ចាសសំរាប់ស្វាមីរបស់ខ្ញុំគាត់មានអាយុ ៦២ ឆ្នាំហើយចាស៕

ក៖
បាទហើយអ្នកមីងមានបានដឹងទេស្រុកកំណើតរបស់ស្វាមីរបស់អ្នកមីងនៅទីកន្លែងណាដែលទៅអ្នកមីង???

ខ៖
ចាសសំរាប់ស្រុកកំណើតរបស់ស្វាមីរបស់ខ្ញុំគឺនៅកម្ពុជាក្រោមតែគ្រាន់តែយើងទាំង២នាក់មកពីស្រុកផ្សេងគ្នាចឹងហាសសំរាប់ប្តីរបស់ខ្ញុំនឹងគឺគាត់នៅស្រុកក្រហើយសំរាប់ខេត្តវិញគឺជាខេត្តកំពុងក្តីហអស់ទេគឺជាឃុំកំពុងក្តីទេចាស៕

ក៖
បាទចឹងស្រុកកំណើតប្តីអ្នកមីងគឺនៅស្រុកក្រឃុំកំពុងក្តីហើយសំរាប់ខេត្តអ្នកមីងមិនបានដឹងទេមែនដែលទេអ្នកមីង???

ខ៖ ចាសសំរាប់ខេត្តវិញគឺខ្ញុំនឹងមិនបានចាំនោះទេចាស៕

ក៖
បាទហើយចឹងនៅពេលដែលស្វាមីរបស់អ្នកមីងនោះទីនោះថាតើគាត់ប្រកមមុខរបបអ្វីដែលទៅអ្នកមីង???

ខ៖

ចាសសំរាប់ស្វាមីរបស់ខ្ញុំនឹងគឺគាត់មិនដែលធ្វើអ្វីនោះទេគឺគាត់ជាទាហ៊ានចឹងគាត់ធ្វើការងារជាទាហ៊ានចាសហើយនៅពេលដែលគាត់បានធ្វើជាទាហ៊ាននឹងគឺគាត់បានទៅរស់នៅខេត្តបាត់ដំបង

ហើយនៅពេលដែលគាត់បានការងារនៅខេត្តបាត់បងនឹងគឺគាត់ចុះមកពីវៀតណាមនឹងគឺគាត់គ្មានលុយសូមប្បីតែមួយរយផងហើយគាត់បានដើរមានគ្នាចំនួន៦រឺក៏៧នាក់ហើយមានម្តាយនឹងឪពុកសរុបទាំងអស់គ្នាមានចំនួន៩នាក់ហើយយើងទាំងអស់គ្នាក៏បានដើលមកអ្នកលឿងហើយនៅពេលដែលយើងបានដើលទៅអ្នកលឿងនឹងគឺយើងទាំងអស់គ្នាចំណាយពេលអស់រយះពេល ៣ថ្ងៃ ៣យប់

ចាសហើយនៅពេលដែលយើងដើលនឹងគឺយើងបានដើលទាំងលុយទឹកហាសចាសហើយនៅពដែលយើងបានដើលនឹងគឺយើងពិបាក់នឹងដើលខ្លាំងណាស់ហើយនៅពេលដែលយើងដើលតាមផ្លូវនឹងគឺមានតាម្នាក់ហើយគាត់បានអោយយើងបានដើលជាមួយគាត់ចឹងហាសហើយនៅពេលដែលទៅដល់ណាគឺយើងនឹងដេកនៅទីកន្លែងនឹងតែម្តងនិយាយទៅដល់វត្តយើងបានសុំគេសំរាក់នៅក្នុងវត្តចឹងហាសចាសហើយនៅពេលដែលយើងបានដេកនៅក្នុងវត្តចឹងគឺយើងគ្មានអ្វីនឹងស៊ីនោះទេហើយនៅពេលដែលបានដេកនៅក្នុងវត្តគឺគេបានដាក់បាយអោយស៊ីចឹងហាសគឺមានលោកម្នាក់ដែលគាត់បានដាក់បាយអោយយើងនឹងហើយនៅពេលនឹងក៏គាត់បានអោយជាអង្ករយើងទៀតទុក្ខសំរាប់ដាំស៊ីតាមផ្លូវចឹងហាសហើយនៅពេលដែលព្រឹកឡើងចឹងទៅគឺយើងនឹងដើរទៀតហើយនិយាយទៅគឺឆ្ងាយខ្លាំងណាស់អូនចាសហើយយើងបានអស់រយះពេល ៣យប់ហើយនឹង៣ថ្ងៃ

ហើយនិយាយទៅកូនចៅរបស់ខ្ញុំនឹងគឺគាត់មានជីវិតនៅទាំងអស់គ្នាចាស៕

ក៖ បាទហើយចឹងនៅពេលដែលអ្នកមីងបានដើលអស់រយះ ៣យប់ហើយនឹង៣ថ្ងៃ បាទចឹងថាតើអ្នកមីងបានជួបបញ្ហាអ្វីទៀតដែលរឺទេអ្នកមីង???

ខ៖

ចាសនិយាយទៅគឺសំរាប់ខ្ញុំនឹងគឺមិនបានជួបអ្វីទៀតនោះទេគឺខ្ញុំនឹងបានជួបតែពួកពោលពតនោះទេពីព្រោះអីនឹងនៅពេលដែលយើងបានដើលនឹងគេបានដូចថាយើងនឹងធ្វើមេទព័ចឹងហាសហើយនៅពេលនឹងគេក៏បានសួរយើងថាយើងនឹងទៅណាហើយយ៉ាងមិចក៏មាននាំកូនទព័នឹងច្រើនម្លេះហើយពេលនឹងគឺយើងមានឆ្នាំងហើយនឹងមានចានចឹងហាសចាសហើយពេលនឹងយើងមិនដឹងធ្វើយ៉ាងមិចពីព្រោះអីនឹងយើងមានចានហើយពេលនឹងគឺគេបានជេម៉ែរបស់យើងទៀតចឹងហាសហើយពេលនឹងគេក៏បានអោយយើងទៅហើយយើងក៏បាននិយាយថាយើងនឹងមិនបានធ្វើអ្វីនោះទេតែពីមុននឹងវាអោយយើងនឹងបានទៅគឺពួកវានឹងបានសួរយើងនឹងច្រើនណាស់ពីព្រោះអីយើងនឹងបានមានចានហើយនឹងមានឆ្នាំងអីចឹងហាសហើយពេលនឹងគឺយើងមានអារម្មណ៍ថាភ័យចឹងហើយពេលនឹងក៏វាបានលេងយើងនឹងបានទៅចាសហើយនៅពេលដែលគេបានលេងយើងនឹងទៅគឺមានគេចំនួន២នាក់ទៀតដែលគេបានដើលតាមយើងចឹងហាសហើយនិយាយសរុបទៅគឺមានមនុស្សចំនួន១១នាក់ដែ

លទៅជាមួយនឹងគ្រួសាររបស់ខ្ញុំនឹងចាសហើយនៅពេលដែលយើងបានដើលដល់អ្នកល្បឿងនឹងយើងបានប្រាប់គេថាចាំគេនឹងទៅយកហើយគេនឹងមិនមែនតូចណាចាសហើយនៅពេលដែលយើងបានដល់កន្លែងគេហើយចឹងគេក៏បានសួរខ្ញុំនឹងទៀតថាសំរាប់ចានឆ្នាំនឹងយកទៅណានឹងហើយនៅពេលដែលគេបានសួរខ្ញុំចឹងហើយខ្ញុំក៏បាននោយាយថាមានយកទៅណាតែប្រសិនជាអ្នកចង់យកក៏យកទៅគឺខ្ញុំបាននិយាយចឹងហាសចាសគឺខ្ញុំសុំតែមួយរស់នោះទេចាសហើយនៅពេលដែលគេបានយកហើយគេក៏បានអោយយើងនឹងបានទៅហើយនៅពេលនឹងគឺយើងចេះតែទៅទៀតចឹងទៅហើយដើលរហូតបានមកដល់ភ្នំពេញនឹងទៅចាសហើយនៅពេលដែលយើងបានមកដល់ភ្នំពេញនឹងគឺយើងមានតែអង្ករតែបន្តិចបន្តួចនោះទេចាសហើយនៅពេលនឹងនៅពេលដែលយើងបានមកដល់ភ្នំពេញហើយគឺយើងបានធ្វើការងារហើយយើងបានទទួលលុយ១០០រៀលក្នុងមួយខែចឹងហាសចាសហើយសំរាប់១០០រៀលនៅក្នុងជំនាន់នឹងគឺវាច្រើនខ្លាំងណាស់ចាសហើយសំរាប់១០០រៀលនឹងអាចទិញមាសបានហាសចាស៕

ក៖
បាទហើយចឹងនៅពេលដែលអ្នកមីងបានទទួលនឹងលុយ១០០រៀលនឹងវាស្មើនឹងប៉ុន្មានជីដែលទៅអ្នកមីង???

ខ៖
ចាសសំរាប់១០០រៀលនៅក្នុងជំនាន់នឹងគឺយើងអាចទិញបានកង់ហើយកង់នឹងវាចាស់ចាស់ដែលចឹងហាសចាសហើយនៅពេលដែលយើងបានទិញកង់នឹងហើយយើងក៏បានទិញបន្លែអីចឹងទៅសំរាប់យកទៅលក់ចឹងហាសចាសហើយនៅពេលដែលយើងបានទិញកង់នឹងហើយយើងចាប់ផ្តើមទិញបន្លែហើយនឹងលក់បន្លែចឹងហាសចាសហើយនៅពេលដែលខ្ញុំនឹងបានជិះកង់ទៅកងពលនឹងហាសគឺប្រហែលជា១០គីឡូរហើយនៅពេលដែលយើងទៅមកនឹងគឺ២០គីឡូរចាសនិយាយទៅនៅពេលដែលខ្ញុំនឹងជិះទៅវិញហើយនឹងទៅមកនឹងគឺទៅជាមួយនឹងប្តីរបស់ខ្ញុំនឹងហាសចាស៕

ក៖
បាទហើយចឹងនៅពេលដែលអ្នកមីងបានរៀបអាពាពិហ៍ពិពាពិហ៍ជាមួយនឹងស្វាមីរបស់អ្នកមីងនៅក្នុងឆ្នាំណាដែលទៅអ្នកមីង???

ខ៖
ចាសនិយាយទៅគឺខ្ញុំនឹងមិនបានចាំថ្ងៃដែលខ្ញុំនឹងបានរៀបអាពាពិហ៍ពិពាពិហ៍ជាមួយនឹងស្វាមីរបស់ខ្ញុំនឹងនោះទេចាស៕

ក៖
បាទហើយចឹងនៅពេលដែលអ្នកមីងបានរៀបអាពាពិហ៍ពិពាពិហ៍ជាមួយនឹងស្វាមីរបស់អ្នក

មីងនឹងថាតើអ្នមីងរៀបអាពាពិហ៍ពិពាពិហ៍ដោយសេចក្ដីស្រលាញ់រឺក៏ឪពុកហើយនឹងម្ដាយរបស់អ្នកមីងគាត់ជាអ្នកបង្ខំអ្នកមីងដែល???

ខ៖
ចាសនៅពេលដែលខ្ញុំបានរៀបអាពាពិហ៍ពិពាពិហ៍ជាមួយនឹងស្វាមីរបស់ខ្ញុំនឹងគឺជាការបង្ខំពីព្រោះនៅក្នុងជំនាន់នឹងគឺឪពុកហើយនឹងម្ដាយគាត់ជាអ្នកសំរេចតែយើងមិនបានរៀបអាពាពិហ៍ពិពាពិហ៍ជាមួយនឹងស្វាមីយើងទេគឺគាត់រៃយើងតែម្ដងហាសចាសនិយាយទៅម្ដាយហើយនឹងឪពុកនឹងគឺគាត់ថាត្រូវតែអោយយើងនឹងយកតែម្ដងចាសនៅក្នុងជំនាន់នឹងគឺសុទ្ធចាប់បង្ខំហាសមិនដូចក្មេងសម័យលូវនឹងទេហាសចាសនិយាយរួមទៅធ្វើយ៉ាងយើងត្រូវតែរៀបអាពាពិហ៍ពិពាពិហ៍ជាមួយនឹងស្វាមីរបស់នឹងតែម្ដងចឹងហាសហើយប្រសិនជាយើងមិនព្រមរៀបអាពាពិហ៍ពិពាពិហ៍ជាមួយនឹងស្វាមីរបស់យើងទេគឺឪពុកហើយនឹងម្ដាយរបស់យើងនឹងគឺគាត់មិនអោយយើងនឹងបានចូលផ្ទះនោះទេចាស៕

ក៖
បាទហើយចឹងនៅពេលដែលអ្នកមីងបានរៀបអាពាពិហ៍ពិពាពិហ៍ជាមួយនឹងស្វាមីចឹងថាតើគេបានអោយថ្លៃបណ្ដាលការទៅដល់អ្នកមីងនឹងចំនួនប៉ុន្មានដែលទៅអ្នកមីង???

ខ៖
ចាសនៅពេលដែលខ្ញុំនឹងបានរៀបអាពាពិហ៍ពិពាពិហ៍ជាមួយនឹងស្វាមីរបស់ខ្ញុំនឹងគឺស្វាមីរបស់ខ្ញុំនឹងគាត់បានអោយថ្លៃបណ្ដាលការចំនួន ៣០០,០០០រៀល
តែប៉ុននោះចាសហាសំរាប់ ៣០០,០០០ នឹងគឺជាលុយរបស់វៀតណាមនោះទេចាស៕

ក៖ បាទហើយចឹងនៅពេលដែលស្វាមីរបស់អ្នកមីងបានអោយលុយ៣០០,០០០
នឹងគឺជាលុយរបស់វៀតណាមប្រសិនជាគិតលុយខ្មែរបានចំនួនប៉ុន្មានដែលទៅអ្នកមីង???

ខ៖ ចាសសំរាប់៣០០,០០០
នឹងគឺជាលុយរបស់វៀតណាមនឹងប្រសិនជានិយាយពីនិយាយពីការទិញបន្លែនឹងក៏វាមិនបានគ្រាប់ចំនួនដែលចាស៕

ក៖ បាទហើយចឹងប្រសិនជា៣០០,០០០
នឹងគឺជាលុយរបស់វៀតណាមនឹងប្រសិនជានិយាយពីនិយាយពីការទិញបន្លែនឹងក៏វាមិនបានគ្រាប់ចឹងថាតើអ្នកមីងបានរៀបអាពាពិហ៍ពិពាពិហ៍នឹងយ៉ាងមិចដែលទៅអ្នកមីង???

ខ៖
ចាសនិយាយទៅគ្រាប់មិនគ្រាប់គេមិនដឹងទេដឹងតែខាងស្រីនឹងជាអ្នកគិតគួរចឹងហាសចាសខ្វះខាតអីគឺខាងស្រីគឺជាអ្នកបន្ថែមទៀតចឹងទៅចាស៕

ក៖
បាទហើយចឹងនៅពេលដែលអ្នកមីងបានរៀបអាពាពិហ៍ពិពាពិហ៍ចឹងអ្នកមីងសល់ប៉ុន្មានខាងស្រីចេញខ្លះចឹងថាតើអ្នកមីងមានភាពលំបាក់ដែលរឺទេក្នុងការបានរៀបអាពាពិហ៍ពិពាពិហ៍នឹងអ្នកមីង???

ខ៖
នៅពេលដែលយើងខ្លះខាតចឹងគឺយើងពិបាក់ដែលហាសមិនមែនលេងសើរនោះទេចាស៕

ក៖
បាទហើយចឹងនៅពេលដែលអ្នកមីងបានរៀបអាពាពិហ៍ពិពាពិហ៍ហើយជួបនឹងបញ្ហាលំបាក់ថាតើអ្នកមីងលំបាក់យ៉ាងមិចដែលអាចប្រាប់ខ្ញុំបានដែលរឺទេអ្នកមីង???

ខ៖
ចាសនិយាយទៅពិបាក់ត្រង់ថានៅពេលដែលគេបានបានរៀបអាពាពិហ៍ពិពាពិហ៍កូនរបស់គេចឹងទៅគឺគេមិនជាសូវខ្វះខាតច្រើននោះទេតែសំរាប់យើងវិញនៅពេលដែលយើងបានរៀបអាពាពិហ៍ពិពាពិហ៍នឹងគឺយើងមានភាពទាបជាងគេហាសហើយសំរាប់ទាបជាងគេនឹងបានន័យថាគេបានរៀបអាពាពិហ៍ពិពាពិហ៍បានលុយសល់ខ្លះហើយសំរាប់យើងនៅពេលដែលបានរៀបអាពាពិហ៍ពិពាពិហ៍នឹងគ្រាន់តែទិញបន្លែនឹងវាមិនគ្រាប់ហើយក៏មិនបានសល់ដូចគេដែលចឹងហាសចាសចឹងហើយជាមូលហេតុយើងលំបាក់ចឹងហាសចាស៕

ក៖
បាទហើយចឹងនៅក្នុងជំនាន់នឹងថាតើអ្នកមីងបានចេញលុយថ្លៃបានរៀបអាពាពិហ៍ពិពាពិហ៍ចំនួនច្រើនដែលទេអ្នកមីង???

ខ៖ ចាសនិយាយទៅយើងចេញដែលតែសំរាប់យើងចេញតែបន្តិចបន្តួចចឹងហាសចាស៕

ក៖
បាទហើយចឹងអ្នកមីងគ្រាន់តែចេញថ្លៃបានរៀបអាពាពិហ៍ពិពាពិហ៍នឹងតែបន្តិចបន្តួចនោះទេបាទហើយចឹងនៅពេលដែលអ្នកមីងនៅកាល់ពីក្មេងនឹងថាតើអ្នកមីងបានសិក្សាបានថ្នាក់ទីប៉ុន្មានដែលទៅអ្នកមីង???

ខ៖
ចាសសំរាប់ខ្ញុំនឹងកាល់ខ្ញុំនៅពីក្មេងនឹងគឺខ្ញុំមិនបានសិក្សាហើយរៀនសូត្រអ្វីនោះទេហើយសំរាប់ខ្ញុំគ្មានចេះអក្សរសូម្បីតែមួយម៉ាត់ហើយសំប្បីតែលេខនឹងក៏ខ្ញុំនឹងមិនបានចេះដែលចឹងហាសចាសនិយាយទៅគឺអត់ចេះតែម្តងហាសហើយសំរាប់ប្រសិនជារៀនគឺខ្ញុំនឹងបានរៀនតែអក្សរវៀតណាមនោះទេចាសពីព្រោះអីខ្មែរយើងមិនបានចូលសាលារៀននោះទេចាសហើយប្រសិនជាអ្នកណាដែលគេចង់រៀននឹងគឺមានតែទៅរៀននៅឯងវត្តនោះទេហើយសំរាប់វត្តនឹងគឺវានៅឆ្ងាយខ្លាំងណាស់ចាសដូចថាយើងដើលពីទីកន្លែងនឹងទៅដល់មានចំងាយ

៣រឺក៏៤គីឡូរជឹងនោះចាសហើយប្រសិនជាយើងដើលចឹងរហូតដល់ម៉ោង១១រឺក៏១២អីនឹងគឺដាច់ខ្យល់ហើយចឹងហាសចាសហើយសំរាប់ចំងាយ៣រឺក៏៤គីឡូរជឹមានជិតឯណាចាសនិយាយទៅគឺមានចំងាយឆ្ងាយណាស់ចាស៕

ក៖

បាទហើយចឹងនៅពេលដែលអ្នកមីងថាតើអ្នកមីងមានអារម្មណ៍យ៉ាងមិចដែលនៅពេលដែលាបានឃើញគេបានទៅរៀនចឹងហាសអ្នកមីង???

ខ៖

ចាសនៅពេលដែលខ្ញុំនឹងបានឃើញគេបានទៅរៀនសូត្រចឹងគឺខ្ញុំនឹងអង្គុយយំហាសចាសហើយសំរាប់សូម្បីតែកូនរបស់ខ្ញុំនឹងរាល់ថ្ងៃនឹងខ្ញុំក្រពេកកូនរបស់២នាក់នឹងគ្មាននាក់ណាមួយចេះអក្សរនោះទេចាសសំរាប់ទី១ហើយនឹងសំរាប់កូនទី២របស់ខ្ញុំនឹងគឺគ្មាននាក់ណាចេះអក្សរនោះទេចាសក្រពេករកអ្វីស៊ីមិនបានផងហើយនិយាយទៅអាកើតកូននឹងក៏វាគ្មានលុយដែលហើយយើងនឹងគឺវាពិបាក់ខ្លាំងណាស់សូម្បីតែយើងទៅរកស៊ីនៅខាងក្រៅនឹងយើងរកបានព្រឹកខ្វះល្ងាចហើយរកបានល្ងាចមកខ្វះព្រឹកវិញចាសនិយាយទៅគឺខ្ញុំនឹងវេទនាណាស់អូនអើយហើយសំរាប់ខ្ញុំនឹងនៅពេលដែលខ្ញុំនឹងបានកើតកូននឹងគឺខ្ញុំមិនដែលបាននៅយូរនោះទេកើតបានកូនចំនួន១០ថ្ងៃអីនឹងគឺខ្ញុំនឹងចុះទៅលក់ត្រីទៀតហើយចាសហើយនឹងដើលរកត្រីហើយនឹងលក់ត្រីហើយនឹងដើលរកទិញម្ហូបសំរាប់ចិញ្ចឹមជីវិតចឹងហាសពីព្រោះអីយើងគ្មានមុខរបបអ្វីនោះទេហើយសំរាប់ស្រែនឹងក៏យើងគ្មានដែលចឹងហាសចាសហើយយើងមានស្រែតិចនឹងគឺគេបានយកអស់ទៀតចឹងហាសចាសនិយាយទៅគឺគេបានដណ្តើមយកអស់ចឹងហាសចាស៕

ក៖

បាទហើយចឹងនៅពេលដែលអ្នកមីងបានទៅរៀនចឹងអ្នកមីងមានអារម្មណ៍ថាយំហើយចឹងអ្នកមីងមានបានសុំឪពុកហើយនឹងម្តាយរបស់អ្នកមីងទៅរៀនដែលរឺទេអ្នកមីង???

ខ៖

ចាសគឺខ្ញុំនឹងបានសុំឪពុកហើយនឹងម្តាយរបស់ខ្ញុំហើយតែគាត់បាននិយាយថាគាត់មិនអោយខ្ញុំនឹងបានទៅរៀននោះទេចាសពីព្រោះអីគាត់បានលឺចាស់ចាស់នឹងនិយាយគ្នាថាសំរាប់កូនស្រីនឹងគឺមិនបាច់អោយទៅរៀននោះទេប្រសិនជារៀនហើយចេះដឹងនឹងគឺសរសេរសំបុត្រអោយសង្សារហើយចឹងហាសចាសហេហេហេនេះហើយជាមូលហេតុដែលឪពុកហើយនឹងម្តាយរបស់ខ្ញុំគាត់មិនបានអោយខ្ញុំនឹងបានទៅរៀននោះទេចាសហើយគាត់បាននិយាយថាសំរាប់ប្រុសប្រុសអោយពួកវារៀនចុះហើយសំរាប់ស្រីស្រីវិញគឺមិនចាំបាច់រៀននោះទេចាសហើយប្រសិនជាអោយកូនស្រីនឹងទៅរៀនហើយនៅពេលដែលវាបានចេះនឹងគឺវានឹងសរសេរសំបុត្រអោយសង្សាររបស់វាហើយចឹងហាសចាសចឹងហើយបានឪពុកហើយនឹងម្តាយរបស់ខ្ញុំគាត់មិនបានអោយខ្ញុំនឹងបានទៅរៀននោះទេចាសហេហេហេចាសគឺគាត់មិន

អោយរៀនពីគាត់ខ្លាចសរសេរសំបុត្រអោយសង្សារចឹងហាក៏ប៉ុនតែសំរាប់កូនប្រុសនឹងគឺគាត់អោយពួកគាត់ទៅរៀនទៅចឹងទៅចាស៕

កៈ
បាទហើយចឹងគឺខ្ញុំចង់សួរអ្នកមីងមួយទៀតចឹងនៅពេលដែលអ្នកមីងមិនបានទៅរៀនចឹងឪពុកហើយនឹងម្តាយរបស់អ្នកមីងគាត់មិនបានអោយខ្ញុំនឹងបានទៅរៀននោះទេចាសហើយចឹងអ្នកមីងអត់ចេះអក្សរចឹងហើយចឹងសំរាប់អ្នកមីងមានបានចេះបានភាសាប៉ុន្មានភាសាដែលទៅអ្នកមីង???

ខៈ
ចាសនិយាយទៅគឺខ្ញុំចេះតែភាសាខ្មែរហើយសំរាប់ភាសាវៀតណាមនឹងគឺខ្ញុំនឹងចេះតែបន្តិចបន្តួចនោះទេចាសពីព្រោះខ្ញុំនឹងបានភ្លេចអស់ហើយចឹងហាសហើយភាសាវៀតណាមសំរាប់ខ្ញុំគឺខ្ញុំនឹងបានមករស់នៅទីកន្លែងនឹងជាង៣០ឆ្នាំហើយចឹងហាសចឹងភ្លេចភាសាវៀតណាមអស់ហើយចាសហើយសំរាប់ភាសាវៀតណាមនឹងនៅពេលដែលគេនិយាយមកចឹងគឺយើងស្តាប់បានខ្លះចឹងហាសក៏ប៉ុនតែសំរាប់ពេលដែលយើងនិយាយទៅគេវិញគឺយើងនិយាយទៅគឺវារឹងរឹងមាត់ចឹងហាសចាសចឹងគឺខ្ញុំនឹងចេះចំនួន២ភាសាចាស៕

កៈ បាទហើយចឹងបានន័យថាអ្នកមីងចេះចំនួន២ភាសាមែនដែលទេអ្នកមីង???

ខៈ ចាសសំរាប់ខ្ញុំគឺខ្ញុំចេះចំនួន២ភាសាចាស៕

កៈ
បាទហើយចឹងអរគុណច្រើនអ្នកមីងហើយចឹងរាល់ថ្ងៃនឹងគឺខ្ញុំចង់និយាយថាអ្នកមីងនៅក្នុងជំនាន់ពោលពតហាសអ្នកមីងថាតើអ្នកមីងបានរស់នៅទីកន្លែងណាដែលទៅអ្នកមីង???

ខៈ
ចាសសំរាប់នៅពេលដែលនៅក្នុងជំនាន់ពោលពតនឹងគឺខ្ញុំនឹងបានរស់នៅស្រុករបស់ខ្ញុំនឹងគឺស្រុកវៀតណាមចាសហើយនៅពេលដែលខ្ញុំនឹងបានទៅរស់នៅស្រុកវៀតណាមនឹងគឺខ្ញុំនឹងបានទៅរស់នៅវាល់ចឹងហាសគឺខ្ញុំនឹងមិនហ៊ានរស់នៅក្នុងភូមិនោះទេចាសពីព្រោះអីនៅក្នុងសម័យដើមនឹងគឺគេមានធ្វើជាសត្វពស់អីចឹងហាសចាសហើយនៅពេលដែលយួនបានចូលមកដល់ចឹងយើងរត់ឆ្លងកាត់វាលស្រែចឹងទៅហើយសំរាប់យើងគឺយើងមិនបានរស់នៅតាមភូមិនោះទេចាសហើយសំរាប់ខ្ញុំគឺខ្ញុំរស់វាល់នឹងចំនួន១ឆ្នាំហាសហើយសំរាប់កាំភ្លើងធំរបស់គេនឹងគឺគេបានបាញ់ទៅហើយយើងក៏បានរត់ចូលទៅក្នុងរុនណ្តៅរបស់គេនឹងទៅហើយសំរាប់រុនណ្តៅរបស់គេគឺវាធំធំណាស់បិនជញ្ជាំងហាសហើយនៅពេលដែលគេបាញ់ចឹងគឺគ្មាននាក់ហ៊ានរស់នៅនោះទេចាសហើយសំរាប់ពេលនឹងក៏យើងនឹងបានទៅរស់នៅវាល់ចឹងទៅហាសចាស៕

ក៖
បាទហើយចឹងនៅក្នុងជំនាន់នឹងគឺគេជំនាន់ពោលពតនឹងថាតើអ្នកមីងបានរស់នៅទីកន្លែងណាដែលទៅអ្នកមីង???

ខ៖ ចាសនៅក្នុងជំនាន់ពោលពតនឹងគឺខ្ញុំនឹងរស់នៅស្រុកវៀតណាមចាស៕

ក៖
បាទហើយចឹងនិយាយថានៅពេលដែលបែកនឹងអ្នកមីងរស់នៅស្រុកវៀតណាមហើយសំរាប់នៅក្នុងជំនាន់ពោលពតវិញហាសអ្នកមីងរស់នៅទីកន្លែងណាដែលទៅអ្នកមីង???

ខ៖
ចាសសំរាប់នៅក្នុងជំនាន់ពោលពតនឹងគឺខ្ញុំនឹងបានរស់នៅស្រុកវៀតណាមហើយនៅពេលដែលខ្ញុំបានរត់ចេញពីស្រុកវៀតណាមគឺខ្ញុំរត់ទៅខាងទន្លេរបិទហាសចាសហើយនៅពេលដែលរស់ចេញពីទន្លេរបិទនឹងនៅពេលដែលបែកពោលពតនឹងគឺយើងបានមួយមួយចឹងហាសហើយសំរាប់ខ្ញុំក៏បានរត់ត្រឡប់ទៅស្រុកវៀតណាមវិញហើយនៅពេលដែលយើងបានរត់ទៅស្រុកវៀតណាមវិញនឹងគឺប្តីរបស់ខ្ញុំនឹងបាននៅរស់ហើយគាត់នឹងថាអោយពួកអារមិចកាំងសងលុយចឹងហាសហើយពួកអារមិចកាំងគេថានឹងសងលុយទៅដល់ប្តីរបស់ខ្ញុំនឹងហើយសំរាប់ប្តីរបស់ខ្ញុំនឹងគឺគាត់ចាំចាំរហូតដល់ប្តីរបស់ខ្ញុំនឹងគាត់ស្លាប់តែម្តងហើយនៅពេលដែលប្តីរបស់ខ្ញុំនឹងបានស្លាប់គឺគេក៏បានសងជំងឺចិត្តដែលចឹងហាសចាសហើយលូវនឹងគឺយើងរកមិនបានឃើញនោះទេនិយាយមានគេបានចូលច្រើនណាស់ហើយសំរាប់ក្រដាសនឹងគឺគេបានស៊ីដាច់បាត់ទៅហើយចាសហើយមានអ្នកខ្លះនឹងគឺគេនឹងបានចង់កាន់អោយតែគ្មាននាក់ហ៊ានកាន់អោយគាត់នោះទេចាសហើយសំរាប់នៅក្នុងជំនាន់នឹងគឺយើងទាំងអស់គ្នានឹងគ្មានបញ្ជីផងនឹងចាសនិយាយទៅគឺគ្មាននោះទេគឺមានតែកាក់សរមួយហើយគេបានចងករបស់គេចឹងទៅដើម្បីនឹងចំណាមហើយគេមានតែអាលុយកូម៉ារបស់គេនឹងចាស៕

ក៖ បាទហើយចឹងលុយកូម៉ានឹងគឺជាលុយជនជាតិអ្វីដែលទៅអ្នកមីង???

ខ៖ ចាសសំរាប់លុយកូម៉ានឹងគឺជាលុយរបស់ជនជាតិអាមេរិចកាំនឹងហាសចាស៕

ក៖
បាទហើយចឹងនៅពេលដែលនៅក្នុងជំនាន់ពោលពតនឹងអ្នកមីងរស់នៅខាសទន្លេរបិទហើយនៅពេលដែលអ្នកមីងរស់នៅខាសទន្លេរបិទថាតើអ្នកមីងបានជួបនឹងបញ្ហាលំបាក់អ្វីខ្លះដែលទៅអ្នកមីងអាចប្រាប់ខ្ញុំបានដែលឬទេអ្នកមីង???

ខ៖
ចាសនិយាយទៅគឺពិបាក់ខ្លាំងណាស់ពីព្រោះអីនឹងគឺគេបានបាញ់គ្នារហូតចឹងហើយសំរាប់ខ្មោចវិញនឹងគឺថាគឺមាននាក់ខ្លះនឹងនៅក្រោមឬស្សីនឹងហើយសំរាប់អ្នកខ្លះទៀតនៅខាងក្រោមផ្ទះចាសហើយនិយាយទៅគឺស្លាប់មនុស្សអស់ច្រើនណាស់ចាសហើយនៅពេលដែ

លខ្ញុំនឹងបានទៅមើលចឹងទៅមាននាក់ខ្លះនឹងសាច់របស់គេនឹងបានធ្លាក់នៅក្នុងគុម្ពឬស្សីចឹងទៅហើយនៅពេលដែលខ្ញុំនឹងបានឃើញចឹងគឺខ្ញុំក៏បានរត់ទៅរស់នៅហើយនឹងធ្វើការងារនៅខេត្តកំពុងចាមចឹងហាសហើយនៅពេលដែលនៅកន្លែងនឹងបានស្ងាត់មកខ្ញុំក៏បានរត់មករស់នៅទីកន្លែងមួយដែលហៅថាភ្នំប្រសិទ្ធយើងនឹងហាសចាសពីដំបូងនឹងគឺខ្ញុំរស់នៅភ្នំបំពុងហាសចាសហើយនៅពេលដែលនៅភ្នំបំពុងនឹងវាពិបាក់ពេកពីព្រោះអីនៅទីកន្លែងនឹងគឺគ្មានទឹកចឹងគឺខ្ញុំនឹងក៏បានរត់មករស់នៅភ្នំទាបវិញហើយនៅពេលដែលខ្ញុំនឹងបានទៅរស់នៅភ្នំទាបនឹងពីដំបូងនឹងយើងបែកនឹងគឺគ្មានទាហ៊ាននោះទេហើយគេវៃវៃគ្នានឹងទីន្លែងអស់រយះពេល៣ខែហាសវៃគ្នាហើយសំរាប់គេវៃគ្នានឹង៣ខែនឹងគឺទាំងយប់ហើយនឹងទាំងថ្ងៃហាសចាសហើយនៅពេលដែលគេបានវៃគ្នាចឹងទៅគឺខ្ញុំនឹងក៏រត់មកវិញហើយនៅពេលនឹងគឺកុំតែបានបងប្អូនជីដូនមួយរបស់ខ្ញុំនឹងនោះទេកុំអីនឹងគឺខ្ញុំនឹងស្លាប់ទាំងអស់គ្នានឹងហាសចាសនិយាយទៅគឺស្លាប់ខ្ទិចប្រសិនជាយើងនឹងមិនរត់នោះទេចាសចុះបើលស្លាប់អស់ហើយចឹងទៅហើយនៅពេលដែលយើងបានរត់ចឹងទៅគឺយើងមិនបានមានអ្វីសំរាប់ហូបនោះទេពីព្រោះអីនឹងគឺខ្មែរក្រហមនឹងវាបានយករបស់យើងនឹងទៅស៊ីអស់ហើយចឹងហាសចាស៕

កៈ
បាទហើយចឹងបងប្អូនរបស់អ្នកមីងដែលគាត់បានស្លាប់នឹងនៅក្នុងជំនាន់ពោលពតនឹងគឺមានចំនួនប៉ុន្មាននាក់ដែលទៅអ្នកមីងអាចប្រាប់ខ្ញុំបានដែលរឺទេអ្នកមីង???

ខៈ
បងប្អូនរបស់ខ្ញុំដែលគាត់បានស្លាប់នឹងនៅក្នុងជំនាន់ពោលពតនឹងគឺមានចំនួន២នាក់ចាសក៏ប៉ុនតែសំរាប់អ្នកដែលរស់នៅជិតខាងនឹងគឺមានគេនឹងបានស្លាប់ច្រើនណាស់ចាសដែលពួកគាត់បានរស់នៅស្រុកជាមួយនឹងគ្នាចឹងទៅចាសក៏ប៉ុនតែបងប្អូនរបស់ខ្ញុំដែលគាត់បានស្លាប់នឹងនៅក្នុងជំនាន់ពោលពតនឹងគឺមានចំនួន២នាក់ចាស៕

កៈ
បាទហើយចឹងបងប្អូនរបស់អ្នកមីងដែលគាត់បានស្លាប់នឹងនៅក្នុងជំនាន់ពោលពតនឹងគឺមានចំនួន២នាក់នឹងគាត់មានឈ្មោះអ្វីដែលទៅអ្នកមីងអ្នកមីងអាចប្រាប់ខ្ញុំបានដែលរឺទេអ្នកមីង???

ខៈ
ចាសបងប្អូនរបស់ខ្ញុំដែលគាត់បានស្លាប់នឹងនៅក្នុងជំនាន់ពោលពតនឹងគឺមានចំនួន២នាក់នឹងទី១គាត់មានឈ្មោះថា មីហ៊ុល
ចាសហើយសំរាប់បងប្អូនរបស់ខ្ញុំដែលគាត់បានស្លាប់នឹងនៅក្នុងជំនាន់ពោលពតនឹងទី២គឺមានឈ្មោះ តុង ចាស៕

កៈ
បាទហើយចឹងបងប្អូនរបស់អ្នកមីងដែលគាត់បានស្លាប់នឹងនៅក្នុងជំនាន់ពោលពតនឹងគឺមានចំនួន២នាក់នឹងប្រុសរឺក៏ស្រីដែលអ្នកមីង???

ខៈ
ចាសបងប្អូនរបស់ខ្ញុំដែលគាត់បានស្លាប់នឹងនៅក្នុងជំនាន់ពោលពតនឹងគឺមានចំនួន២នាក់នឹងគឺសុទ្ធតែស្រីទាំងអស់នឹងចាសនិយាយទៅគឺខ្ញុំមានតែបងប្អូនតែ២នាក់នឹងនោះទេហើយសំរាប់ម្តាយហើយនឹងឪពុកនឹងគឺគាត់ទាំង២បានស្លាប់អស់ហើយចឹងហាសចាសនិយាយទៅដូចតែកូនកំព្រាដែលនឹងទាំង២នាក់នឹងដែលស្លាប់ហាសចាស៕

កៈ
បាទហើយចឹងនៅពេលដែលគាត់បានស្លាប់ចឹងថាតើអ្នកមីងមានបានយកគាត់ទាំង២នាក់នឹងយកទៅធ្វើបុណ្យដែលរឺទេអ្នកមីង???

ខៈ
ចាសនៅពេលដែលបងប្អូនរបស់ខ្ញុំនឹងគាត់បានស្លាប់ទាំង២នាក់នឹងបានស្លាប់នឹងគឺខ្ញុំនឹងមិនបានយកគាត់នឹងទៅធ្វើបុណ្យនោះទេចាសពីព្រោះអីនឹងគឺគេមិនបានអោយយើងនឹងបានយកសពនឹងយកទៅធ្វើបុណ្យនោះទេហើយនៅពេលដែលបងប្អូនរបស់ខ្ញុំនឹងគាត់បានស្លាប់ទាំង២នាក់នឹងបានប្រហែលជាបាន១០ថ្ងៃអីនឹងគឺខ្ញុំបានត្រឡប់ទៅស្រុកវៀតណាមរបស់ខ្ញុំវិញពីដំបូងគឺគេមិនអោយយើងទៅនោះទេចាសគេថាទាល់តែយើងនឹងមានអ្វីស្អីនោះទេបានគេនឹងអោយយើងទៅចឹងហាសចាសហើយពេលនឹងរហូរដល់៣យប់៣ខែហាសនិយាយទៅគឺ៣យប់៣ខែហើយនឹងមានប៉ុន្មានថ្ងៃទៀតហាសបានបែកចឹងពីព្រោះអីនឹងមានទាហ៊ាននៅលើភ្នំប្រសិទ្ធនឹងមានចំនួនច្រើនណាស់ហើយនិយាយទៅគឺស្លាប់ច្រើនតែម្តងហាសចាសហើយសំរាប់មួយថ្ងៃមួយថ្ងៃនឹងគឺគេបានសែនសាក់សពនឹងមក១០រឺក៏២០នាក់អីចឹងពីព្រោះអីនឹងខ្មែរក្រហមនឹងនៅលើភ្នំនឹងច្រើនហើយសំរាប់នៅលើភ្នំនឹងមានសុទ្ធតែទឹកចឹងហើយសំរាប់យើងយើងគ្មានទឹកសំរាប់ហូបនោះទេហើយនៅពេលដែលយើងបានទៅដងទឹកនៅលើភ្នំនឹងគឺពួកវាបានបាញ់សំលាប់ក្នុងមួយមួយថ្ងៃនឹងគឺស្លាប់២នាក់រ៏ក៏៣នាក់ចឹងទៅហើយនៅពេលដែលយើងដងមិនបានក៏វាបាញ់សំលាប់ដែលចឹងហាសចាស៕

កៈ បាទហើយចឹងនៅទីកន្លែងនឹងមានទាហ៊ានមានគេយាមមែនដែលទេអ្នកមីង???

ខៈ
ចាសនិយាយទៅគឺមានគេយាមនៅស្រះទឹកនឹងតែម្តងហើយយើងប្រសិនជាគ្មានទឹកយើងក៏ស្លាប់ដែលចឹងហាសចាសហើយនៅពេលដែលយើងបានទៅដងទឹកនឹងគឺពួកវាបានជំរងយើងហើយនឹងបាញ់យើងហើយតែសំរាប់យើងទាំងអស់គ្នានឹងមាននាក់ខ្លះនឹងគឺគេទៅដងទឹកនឹងនៅតែពេលយប់នោះទេហើយសំរាប់ពេលថ្ងៃនឹងគឺយើងសំរាប់ចឹងហាសចាសហើយពេលនឹងយើងក៏បានត្រឡប់មកវិញហើយរយះពេលដែលយើងបានដើលនឹងគឺអស់រយះ

ពេល៧ថ្ងៃហើយនឹង៧យប់ចាសគឺគេបានរែមកដល់ឧដ្ដុងនឹងហើយនៅពេលដែលគេបានបាញ់មកដល់ឧដ្ដុងនឹងគឺថាអាវល្លអីគេនឹងគឺថាឆ្អិនសាច់អស់ហើយសំរាប់សាច់ចាសដូចថាសាច់របស់យើងវាដូចជាឆ្អិនចឹងហាសនឹងហើយ៕

កៈ
បាទហើយចឹងនៅពេលដែលប្ដីរបស់អ្នកមីងគាត់បានរត់អស់រយៈពេល៧ថ្ងៃហើយនឹង៧យប់នឹងថាតើពួកគាត់បានសំលាប់ប្ដីរបស់អ្នកមីងដែលរឺទេអ្នកមីង???

ខៈ
ចាសនៅពេលដែលប្ដីរបស់ខ្ញុំនឹងបានរត់អស់រយៈពេល៧ថ្ងៃហើយនឹង៧យប់នឹងគឺសំលាប់ប្ដីរបស់ខ្ញុំនឹងអត់បាននោះទេចាសតែគ្រាន់តែថាប្ដីរបស់ខ្ញុំនឹងគឺគាត់បានរត់ហើយនឹងនៅសំរាក់នៅក្នុងព្រៃដែលនៅជិតជិតចឹងហាសចាសហើយរហូតដល់ពេលយប់នឹងបានគាត់ចេញដល់មកទៀតចឹងទៅហើយសំរាប់ពេលថ្ងៃនឹងគឺគាត់មិនហ៊ានចេញនោះទេពីព្រោះអីមានសុទ្ធតែទាហ៊ានខ្មែរក្រហមទាំងអស់នឹងចាស៕

កៈ
បាទហើយចឹងអរគុណច្រើនអ្នកមីងហើយចឹងសំរាប់អ្នកមីងវិញនៅពេលដែលអ្នកមីងនៅក្នុងជំនាន់ពោលពតថាតើគេមានអោយអ្នកមីងធ្វើការងារអ្វីដែលលំបាក់លំបាក់ដែលរឺទេអ្នកមីង???

ខៈ
ចាសនៅក្នុងជំនាន់ពោលពតនឹងគឺគេបានអោយខ្ញុំនឹងទៅរែកបន្លែហើយនឹងធ្វើការងារផ្សេងផ្សេងដែលលំបាក់ចឹងហាសតែគឺខ្ញុំនឹងគឺមិនបាននៅនោះទេគឺខ្ញុំនឹងបានរត់ទៅរស់នៅស្រុកវៀតណាមរបស់ខ្ញុំវិញហើយចឹងហាសចាសហើយពេលនឹងគេអោយខ្ញុំនឹងធ្វើការងារច្រើនណាស់ក៏ប៉ុនតែខ្ញុំមិនធ្វើគឺខ្ញុំនឹងបានរត់ទៅរស់នៅស្រុកវៀតណាមរបស់ខ្ញុំវិញចាស៕

កៈ
បាទហើយចឹងនៅដែលអ្នកមីងបានរត់ទៅនៅស្រុកវៀតណាមនឹងថាតើអ្នកមីងបានជួបនឹងបញ្ហាលំបាក់អ្វីខ្លះដែលទៅអាចប្រាប់ខ្ញុំបានដែលរឺទេអ្នកមីង???

ខៈ
ចាសនិយាយទៅគឺយើងពិបាកដែលចឹងហាសចាសនៅពេលដែលយើងបានទៅនឹងគឺថាពួកវាបានចាប់យើងនឹងម្ដងចឹងហាសហើយពេលនឹងគឺវាបាននិយាយថាយើងនឹងគឺជាខ្មែរសេរីចឹងហាសហើយនៅពេលដែលវាបានចាប់យើងហើយចឹងគឺវាបានអោយយើងនឹងទៅជីកបន្លែអីចឹងទៅហើយរហូតដល់២សប្ដាហ៍អីចឹងបានវាអោយយើងនឹងបានមកដល់ផ្ទះវិញចឹងហាសចាសនិយាយទៅគឺពិបាក់ខ្លាំងណាស់នៅពេលដែលខ្ញុំនឹងបានទៅរស់នៅស្រុកវៀតណាមចាស៕

កៈ
បាទហើយចឹងនៅពេលដែលអ្នកមីងបានរស់នៅក្នុងជំនាន់ពោលពតនឹងអ្នកមីងមើលទៅដូចជាមិនសូវជាស្រួលនោះទេមែនដែលទេអ្នកមីង???

ខៈ
ចាសនិយាយទៅគឺពិបាក់ខ្លាំងណាស់ហើយនៅពេលដែលខ្មែរក្រហមនឹងបានចូលមកក៏នេះដែលចឹងហាសចាសហើយគេបាននិយាយថាមូលថៃមូលផង៕

កៈ បាទហើយចឹងអានឹងបានន័យថាយ៉ាងមិចដែលទៅអ្នកមីង???

ខៈ
ចាសនឹងបានន័យថានៅពេលដែលបានបែកហើយចឹងនៅពេលដែលទាហ៊ានខ្មែរចូលមកតែគេបានចូលទៅធ្វើជាទាហ៊ានយួនដ៏ដែលចឹងហាសចាសហើយនៅពេលដែលយើងបានទៅដល់ស្រុកយួនហើយចឹងគឺយើងមាន២ប្រភេទចឹងហាសអា១នឹងគឺនៅក្នុងព្រៃហើយសំរាប់អា១ទៀតនឹងគឺវាបានរស់នៅក្នុងភូមិចឹងហាសនឹងហើយចាសនឹងនៅភូមិគឺគេបានហៅយ៉ាងដូចថ្នឹងចាស៕

កៈ
បាទហើយចឹងសំរាប់ទាហ៊ានដែលនៅក្នុងភូមិសាហាវជារឺក៏ជាទាហ៊ាននៅក្នុងភូមិគេសាហាវជាអ្នកមីង???

ខៈ
ចាសនិយាយទៅទាហ៊ាននៅក្នុងព្រៃនឹងគឺសាហាវខ្លាំងណាស់ណាដូចថាអូនឯងនឹងបានចូលទៅធ្វើជាទាហ៊ានរបស់យួនចឹងហើយខ្មែរក្រហមនឹងបាននិយាយថាកុំអោយកូននឹងបានធ្វើជាទាហ៊ានចឹងគឺគេនឹងចាប់ចឹងហាសហើយប្រសិនជាយើងនឹងមិនទៅហៅនោះទេគឺគេនឹងចាប់យើងនឹងទៅបិទភ្នែកនឹងគឺឪពុកហើយនឹងម្តាយរបស់យើងនឹងហាសចាសនិយាយទៅគឺវាមិនធម្មតាណាហើយនៅពេលដែលខ្ញុំនឹងបានលឺចឹងទៅគឺខ្ញុំក៏បានឈប់ធ្វើចឹងទៅហើយសំរាប់ខាងវាវិញចឹងហាសនៅពេលដែលដល់ពេលយប់យប់វិញគឺថាយើងនឹងចង់ខ្លាចវិញហាសអូនហើយនៅពេលដែលយើងបានលឺសំលេងរបស់វានឹងគឺថាយើងបានអោបហើយនឹងអាកញ្ជាប់នឹងគឺយើងបានអោបចាសហើយសំរាប់ខ្មែរក្រហមនឹងគឺគេបានហៅគាត់ថាយៀកមីងចាសយៀកមីងនឹងគឺនៅក្នុងជំនាន់របស់ខ្ញុំនឹងហាសយៀកមីងយៀងកុងនឹងហាសហេហេហេ៕

កៈ
បាទហើយចឹងគឺខ្ញុំចង់សួរអ្នកមីងមួយទៀតថាតើនៅពីក្មេងនឹងអ្នកមីងចូលចិត្តច្រៀងបទចំរៀងអ្វីដែលទៅអ្នកមីង???

ខៈ ចាសនិយាយទៅពីបទចំរៀងនឹងគឺខ្ញុំមិនចេះច្រៀងនោះទេចាស៕

កៈ
បាទហើយចឹងអ្នកមីងមិនបានចេះច្រៀងនោះទេហើយចឹងនៅពីក្មេងនឹងថាតើគេមានបទចំរៀងអីដែលរឺទេហើយនឹងមានបទចំរៀងមួយណាដែលអ្នកមីងចូលចិត្តដែលរឺទេអ្នកមីង???

ខៈ
ចាសអាមួយនឹងក៏អត់មានដែលចាសអាអូនអើយនៅក្នុងជំនាន់នឹងគឺយើងទាំងអស់គ្នាកំសត់ទៅរកចំរៀងអីនឹងពីណាមកចាសហើយសំរាប់ជំនាន់នឹងក៏គ្មាននាក់ណាដែលបានចេះច្រៀងដែលចឹងហាសហើយសំរាប់ពេលសម័យនឹងគឺមានគេខ្លះនឹងគឺគេបានចូលចិត្តចឹងទៅចាស៕

កៈ
បាទហើយចឹងគឺថាខ្ញុំចង់សួរសំណួរជាចុងក្រោយទៅកាន់អ្នកមីងថាតើអ្នកមីងមានពាក្យអ្វីដែលនឹងផ្ដែលផ្ដាំទៅកាន់កូនចៅរបស់អ្នកមីងនៅពេលដែលគេបានលឺរបស់អ្នកមីងហើយចឹងថាតើអ្នកមីងមានពាក្យអ្វីដែលនឹងផ្ដែលផ្ដាំទៅកាន់កាន់គាត់ដែលរឺទេអ្នកមីង???

ខៈ
ចាសសំរាប់ខ្ញុំគឺខ្ញុំគ្រាន់តែផ្ដែលផ្ដាំទៅកាន់កូនចៅរបស់ខ្ញុំថាប្រសិនជាមានដូចនៅក្នុងជំនាន់របស់ខ្ញុំនឹងគឺថាខ្ញុំមិនចង់អោយពួកគាត់បានឃើញនោះទេចាសហើយគ្រាន់តែសូមអោយគាត់នៅក្នុងជំនាន់ដែលសប្បាយសប្បាយហើយនឹងធ្វើការងាររៀនសូត្រហើយសំរាប់រឿងកាប់ចាក់ហើយនឹងជុកគ្រឿងញៀននឹងគឺខ្ញុំនឹងមិនចង់ជាអោយពួកគាត់នឹងបានឃើញនោះទេចាសហើយសំរាប់រាល់ថ្ងៃនឹងគឺថាខ្ញុំខំធ្វើបុណ្យខ្លាំងណាស់បានកូនរបស់ខ្ញុំទាំង៧នាក់នឹងគឺគេមានជីវិតរស់នៅទាំងអស់គ្នាចឹងហាសកុំអោយវេទនាទៀតពីព្រោះអីនឹងគឺថាខ្ញុំនឹងមិនចង់បានភាពវេទនានោះទេហើយសូម្បីតែរាល់ថ្ងៃនឹងយើងមានសេរីភាពដោយខ្លួនឯងនឹងគឺថាយើងនឹងមានសំណាងហើយចឹងហាសមិនបាច់ហើយកំលាំងណាមកជួយនោះទេហើយសំរាប់កំលាំងដៃលើយើងបានមានគឺថាយើងធ្វើការងាររកស៊ីខ្លួនឯងទៅចុះចាសហើយសំរាប់នៅពេលដែលខ្ញុំនឹងបានមករកនៅទីកន្លែងនឹងមកគឺខ្ញុំមិនបានទៅសុំគេទុក្ខសំរាប់ហូបនោះចាស

កៈ
បាទហើយចឹងសង្ឃឹមថានៅពេលដែលគាត់បានលឺសំលេងរបស់អ្នកមីងហើយសូមអោយគាត់ជួយហើយនឹងខំប្រឹងប្រែងខ្លួនឯងដើម្បីអោយអាបបានគោរពឪពុកហើយនឹងម្ដាយហើយនឹងកុំទៅធ្វើអ្វីដែលមិនល្អសំរាប់គ្រួសារចឹងហាសបាទ???

ខៈ
បាទហើយសំរាប់សម័យនឹងទៅហើយសូមកុំអោយគាត់នឹងបានទៅធ្វើអ្វីដែលមិនល្អហើយនឹងបានចេញឆ្ងាយពីគ្រឿងញៀនមិនបានដឹងគុណម្ដាយហើយនឹងឪពុកចឹងហាសខ្វះអីកូនវៃម្ដាយហើយនឹងឪពុកចឹងហាសសំរាប់ខ្ញុំនឹងគឺខ្ញុំមិនចង់អោយឃើញយ៉ាងដូចថ្មឹងនោះទេគឺ

ខ្ញុំចង់អោយមានកូនដែលមានចិត្តធម៌ចាសសូមអោយកូនមានមានចិត្តធម៌សំរាប់ឪពុកហើយនឹងម្ដាយអីចឹងទៅហាសចាស៕

ក៖
បាទហើយចឹងសំរាប់អ្នកមីងមានអ្វីនឹងផ្ដែលផ្ដាំទៀតទេទៅកាន់កូនចៅរបស់អ្នកមីងទៀតដែលរឺទេអ្នកមីង???

ខ៖ ចាសសំរាប់ខ្ញុំគឺខ្ញុំសូមផ្ដែលផ្ដាំទៅកូនចៅរបស់ខ្ញុំនឹងតែប៉ុននឹងនោះទេចាស៕

ក៖
បាទហើយចឹងអត់អីទេអ្នកមីងហើយចឹងសង្ឃឹមថានៅពេលដែលគាត់បានលឺសំលេងរបស់អ្នកមីងចឹងទៅសូមអោយគាត់អាចគេចអោយផុតពីគ្រឿងញៀនហើយចឹងសង្ឃឹមថាគាត់អាចធ្វើជាមនុស្សល្អចឹងហើយក៏ជាកូនល្អហើយនឹងជាប្រជាពលរដ្ឋដែលល្អចឹងហាសបាទហើយចឹងសំរាប់ថ្ងៃនឹងគឺខ្ញុំមានតែប៉ុននឹងហើយអរគុណច្រើនមែនទែនអ្នកមីងសំរាប់មានការពិភាក្សាហើយនឹងជជែកគ្នាហាស???

ខ៖
ចាសហើយសំរាប់ខ្ញុំគឺខ្ញុំនឹងចង់សប្បាយមិនចង់មានទុក្ខនោះទេហើយទោះមានតិចអីនឹងគឺខ្ញុំនឹងបានខ្លាចហើយចឹងហាសពីព្រោះអីនឹងកូនប្រុសរបស់ខ្ញុំនឹងមានចំនួន៥នាក់ហាសចាសហើយគឺខ្ញុំនឹងមិនដែលមាននាក់មានមាត់តូចធំអីនោះទេចាសពីព្រោះអីនឹងដូចថាយើងមានស៊ីអត់ស៊ីអីគឺយើងធ្វើចេញពីកំលាំងរបស់យើងចឹងហាសអានឹងបានគេហៅថាល្អហើយប្រសិនជាកូនរបស់ខ្ញុំនឹងទៅលួចគេគឺខ្ញុំនឹងសុខចិត្តស្លាប់គឺខ្ញុំមិនអោយរបស់ខ្ញុំនឹងទៅលួចគេនោះទេចាសហើយនិយាយទៅគឺខ្ញុំបានផ្ដាំទៅកាន់កូនរបស់ខ្ញុំនឹងរាល់ថ្ងៃនឹងចាសហើយប្រសិនជាអត់មានខ្ញុំនឹងកូនប៉ុន្មាននាក់នឹងគឺមិនអោយធ្វើអីដែលមិនល្អចឹងហាសចាសហើយសំរាប់កូនរបស់ខ្ញុំនឹងវាកំធ្វើការងារអីនឹងហើយសំរាប់គ្រឿងញៀននឹងគឺថាប្រសិនជាវាធ្វើខ្ញុំនឹងថាវានឹងជាចោលចឹងហាសចាសហើយសំរាប់ចៅរបស់ខ្ញុំនឹងមានចំនួន២០នាក់ទៀតហាសនឹងសំរាប់ចៅរបស់ខ្ញុំនឹងហាសចាសហើយអូនឯងគិតមើលម្នាក់៣រឺ៤នាក់៕

ក៖ បាទហើយចឹងអរគុណណាស់អ្នកមីងបាទហើយចឹងខ្ញុំជំរាបលាអ្នកមីងបាទ៕